# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀង
## រវាងបុគ្គលិកសណ្ឋាគារ សុខាសៀមរាប
## និងនិយោជកនៃសណ្ឋាគារ សុខាសៀមរាប

អនុស្សរណៈនៃការយោគយល់នេះត្រូវបានធ្វើឡើងនៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ រវាងបុគ្គលិកនៃសណ្ឋាគារ សុខាសៀមរាប (ពីនេះតទៅហៅថា "**និយោជិត**") និងតំណាងសណ្ឋាគារ សុខាសៀមរាប (ពីនេះតទៅហៅថា "**និយោជក**")។

ដោយសារតែមកទល់ពេលនេះស្ថានភាពជម្ងឺកូវីត ១៩ នៅទូទាំងពិភពលោកនាពេលនេះនៅពុំទាន់ថមថយ ហើយក៏មិនទាន់មានឱសថជាក់លាក់សម្រាប់ព្យាបាលប្រកបដោយប្រសិទ្ធភាព និងមិនទាន់មានវ៉ាក់សាំងចាក់ការពារជម្ងឺនេះនៅឡើយ។ បញ្ហានេះបានធ្វើឲ្យសេដ្ឋកិច្ច និងដំណើរការអាជីវកម្មពិភពលោកទាំងមូលស្ថិតក្នុងភាពពុំប្រកដប្រជាដែលពិបាកនឹងព្យាករណ៍បំផុត។ ហេតុដូចនេះ ដើម្បីសម្រាលនូវបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរនៅចំពោះមុខនេះ តំណាងនិយោជក និងនិយោជិតបានចរចារ និងព្រមព្រាងគ្នាឲ្យរកិច្ចសន្យាការងារ ហើយស្នើសុំអោយនិយោជិតសម្រាកពីការងារដោយឥតប្រាក់ឈ្នួលរយៈពេល ៥២ ថ្ងៃបន្ថែមទៀត គិតចាប់ពីថ្ងៃទី១០ ខែមិថុនា ដល់ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០។

ភាគីទាំងពីរបានព្រមព្រៀងគ្នា លើលក្ខខណ្ឌដូចខាងក្រោម៖

- និយោជិតដែលត្រូវបានដាក់ឲ្យឈប់សម្រាកពីការងាររយៈពេល ៥២ ថ្ងៃ នឹងមិនទទួលបានប្រាក់ឈ្នួល និងប្រាក់ធានានុគ្រោះទេ នៅក្នុងអំឡុងពេលនៃការឈប់សម្រាកនេះ។
- អតីតភាពការងាររបស់និយោជិតដែលដាក់ឲ្យឈប់សម្រាកដោយឥតប្រាក់ឈ្នួល នឹងមិនត្រូវបានប៉ះពាល់ឡើយ។

ចំពោះនិយោជិតដែលត្រូវរក្សាទុកក្នុងចំនួនអប្បបរមា ទៅតាមតម្រូវការជាក់ស្តែងនៃផ្នែកនិមួយៗ ដើម្បីបំពេញការងារក្នុងកំឡុងពេលផ្អាកដំណើរការអាជីវកម្មមានដូចខាងក្រោម៖

១. និយោជិតធម្មតាចំនួន ៩៨ នាក់ តម្រូវអោយធ្វើការពេញម៉ោងនឹងទទួលបាន ប្រាក់ឈ្នួល ១០០% ព្រមទាំងប្រាក់ឧបត្ថម្ភអាហារចំនួន ២.០០ដុល្លារអាមេរិក សម្រាប់ ១ថ្ងៃធ្វើការ។

២. បុគ្គលិកចំនួន ០៥ នាក់ តម្រូវឲ្យធ្វើការប្រាំបី (៨) ថ្ងៃក្នុងមួយខែ នឹងទទួលបានប្រាក់ឈ្នួលទៅតាមចំនួនថ្ងៃធ្វើការជាក់ស្តែង ព្រមទាំងប្រាក់ឧបត្ថម្ភអាហារចំនួន ២.០០ ដុល្លារអាមេរិក សម្រាប់ ១ថ្ងៃធ្វើការ ក្នុងនោះរួមមាន៖

- បុគ្គលិកផ្នែកហិរញ្ញវត្ថុ ចំនួន ០២នាក់

- បុគ្គលិកផ្នែកធនធានមនុស្ស ចំនួន ០២នាក់

- បុគ្គលិកផ្នែកព័ត៌មានវិទ្យា ចំនួន០១នាក់

៣. បុគ្គលិកចំនួន ០៥ នាក់ តម្រូវឲ្យឈប់សម្រាកដោយគ្មានប្រាក់ឈ្នួលរយៈពេល ៥២ ថ្ងៃ បន្តទៀត ចាប់ពីថ្ងៃទី១០ ខែមិថុនា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០។ ក្នុងនេះរួមមានៈ

- បុគ្គលិកផ្នែកបម្រើអាហារ និងភេសជ្ជៈ ចំនួន ០៣នាក់

- បុគ្គលិកផ្នែកគេហកិច្ច ចំនួន ០២នាក់

សូមបញ្ជាក់ថា ចំណុចដូចដែលបានរៀបរាប់ខាងលើនេះ គឺសម្រាប់ការអនុវត្តរយៈពេល ៥២ ថ្ងៃ គិតចាប់ពីថ្ងៃទី១០ ខែមិថុនា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០។ ក្រុមហ៊ុននឹងធ្វើការជូនដំណឹងជាថ្មី ប្រសិនបើស្ថានការណ៍មានការប្រែប្រួល ហើយគូភាគីនឹងពិនិត្យមើលអនុស្សរណៈនៃការយោគយល់នេះ ពីខាងក្រោមនេះ៖

**ហត្ថលេខាភាគីតំណាងនិយោជក**

ហង្ស វណ្ណះ

**ហត្ថលេខាភាគីនិយោជិត**

លី សត្យា ________ 01.06.20

អង បុប្ផា ________ Bopha 01-06-20

ង៉ែត សុខា ________ 01.06.20

អ៊ូ ជីញសា ________ 01.06.20

វី វណ្ណះ ________ 01.06.20

ឡាយ ចាន់ថ្លា ________ 02.06.20

ចាន់ ប៊ុនថុង ________

ចាន់ ប៊ុនធារ ________

ឌួន ~~ជួម~~ សុធា ________ 02-06-20

ផ្លិត ប៊ុ ________ 02.6.20